**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០១ បប**

# បទបញ្ជា
## ស្តីពី
## ការបញ្ឈប់ការទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់ពីបរទេស

កន្លងមករាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជាស្តីពីការទប់ស្កាត់ការនាំចូលសាច់ និងសត្វជ្រូករស់ពីបរទេស ដែលសំដៅបំបាត់ចលនានាំចូលសាច់ និងសត្វជ្រូករស់បែបអនាធិបតេយ្យ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងសត្វក៏ជាការសំដៅរក្សាបាននូវសុខភាពសាធារណៈ ។ ទន្ទឹមនឹងការទប់ស្កាត់ការនាំចូលសាច់ និងសត្វជ្រូករស់នេះ រាជរដ្ឋាភិបាលក៏បានពង្រឹងសមត្ថភាពគ្រប់គ្រង ក៏ដូចជាសមត្ថភាពជំនាញបច្ចេកទេសរបស់មន្ត្រីជំនាញមានសមត្ថកិច្ច ដើម្បីសំរួលដល់ការធ្វើពាណិជ្ជកម្មសាច់ និងសត្វជ្រូករស់នេះផងដែរ ។ បច្ចុប្បន្នរាជរដ្ឋាភិបាលបានវាយតំលៃឃើញថា សមត្ថកិច្ចជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថភាពក្នុងការត្រួតពិនិត្យអនាម័យ និងភូតគាម-អនាម័យលើផលិតផលកសិកម្មបានហើយ ។ ដូចនេះ រាជរដ្ឋាភិបាលសំរេចដាក់ចេញនូវបទបញ្ជាថ្មីដូចខាងក្រោម :

១-បញ្ឈប់ការទប់ស្កាត់ការនាំចូលសាច់ និងសត្វជ្រូករស់ពីបរទេស ។ បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ១៣ ខែ សីហា ឆាំ ២០០៧ ស្តីពីការទប់ស្កាត់ការនាំចូលសាច់ និងសត្វជ្រូករសពីបរទេសត្រូវទុកជានិរាករណ៍ ។

២-រាល់ការនាំចូលសាច់ សត្វជ្រូករស់ ព្រមទាំងផលិតផលកសិកម្មទាំងអស់ត្រូវអនុវត្តតាមនីតិវិធីកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានដែលពាក់ព័ន្ធនានាជាធរមាន ។

៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យការនាំចូលផលិតផលកសិកម្មទាំងអស់ ពិសេសការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យលើផលិតផលកសិកម្ម ។

៤-ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការត្រួតពិនិត្យ និងអនុវត្តវិធានអនាម័យ និងភូតគាមអនាម័យឱ្យបានត្រឹមត្រូវតាមបច្ចេកទេសលើរាល់ផលិតផលកសិកម្មដែលនាំចូលពីបរទេស ។

ទទួលបានបទបញ្ជានេះ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៨*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ